# មេរៀនទី ៣១៖ ណូអេសង់ទូកធំមួយ

[លោកុប្បត្តិ ៦៖៥-២២]

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ [https://youtu.be/H1VRCcsF1SM](https://youtu.be/H1VRCcsF1SM)

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** [https://youtu.be/AdWVEpiSGyI](https://youtu.be/AdWVEpiSGyI)

**គោលបំណង៖ ព្រះតែងតែត្រឹមត្រូវ។**

**ខគម្ពីរចងចាំ៖ លោកកុប្បត្តិ ៦៖២២** *"ណូអេក៏ធ្វើដូច្នោះ តាមគ្រប់ទាំងសេចក្ដីដែលព្រះបានបង្គាប់គាត់ធ្វើការនោះសំរេចទាំងអស់។"*

**ចំរៀង** ( *យូធូបលីង* )៖

១. លោកតាណូអេ https://youtu.be/97I8ePxrQ7s

២. កូនតូចៗអើយ https://youtu.be/ewu6Tfpo5Vo

៣. ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ https://youtu.be/I-PzUIJ0MVo

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «ជិះទូក»




១. ឲ្យកុមារគ្រប់គ្នាឈរនៅកណ្ដាលថ្នាក់រៀន

២. កុមារត្រូវរត់រកគ្នាតាមចំនួន លេខដែលគ្រូហៅ។ ឧទាហរណ៍៖ នៅពេលដែលគ្រូនិយាយថា "ជិះទូក២នាក់" កុមារត្រូវរកដៃគូពីរៗនាក់ហើយឈរកាន់ដៃគ្នា។ ប្រសិនបើគ្រូ និយាយថា "ជិះទូកគ្នា ៧នាក់" នោះកុមារត្រូវរត់រក គ្នាឲ្យបាន៧នាក់ហើយឈរជាមួយគ្នា។ ប្រសិនបើកុមារមិនអាចស្វែករកដៃគូរឲ្យបានដូចលេខដែលគ្រូនិយាយទេនោះ នោះពួកគេនឹងចាញ់ល្បែងនេះ។

៤. បន្តលេងល្បែងនេះរហូតនៅសល់កុមារតែ២នាក់ នោះពួកគេជាអ្នកឈ្នះល្បែងនេះ។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា វាគឺពិតជាមានសារៈសំខាន់ខ្លាំង ណាស់ក្នុងការស្ដាប់គ្រូ ពីព្រោះគ្រូមានចម្លើយដ៏ត្រឹមត្រូវ។ ក៏ដូចគ្នានេះដែលយើងត្រូវតែស្ដាប់បង្គាប់ព្រះ ពីព្រោះទ្រង់តែងតែត្រឹមត្រូវជានិច្ច។

### ៤. ការណែនាំមេរៀន

តើធ្លាប់មាននរណាម្នាក់ស្នើរសុំឲ្យអ្នកធ្វើនូវរឿងដែរមិនអាចទៅរួចដែរឬទេ? ចុះប្រសិនបើខ្ញុំសុំអ្នកឲ្យហោះនោះ? តើអ្នកនឹងស្ដាប់តាមខ្ញុំដែរឬទេ? អ្នកនឹងមិនស្ដាប់តាមខ្ញុំនោះទេ ព្រោះខ្ញុំបានសុំឲ្យអ្នកធ្វើនូវរឿងដែលមិនអាចទៅរួច ពេលខ្លះមនុស្សគឺមិនអាចធ្វើការនោះបាននោះទេ។ ប៉ុន្តែនៅពេលដែលព្រះបានប្រាប់ឲ្យអ្នកធ្វើអ្វីមួយនោះ អ្នកអាចប្រាកដបានថា ការទាំងនោះអ្នកអាចធ្វើវាបាន។ ថ្ងៃនេះយើងនឹងរៀនពីបុរសម្នាក់ដែលបានធ្វើតាមបង្គាប់របស់ព្រះ បើទោះបីជារឿងនោះ មើលទៅហាក់បីដូចជាមិនអាចទៅរួចក៏ដោយ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

បន្ទាប់ពីអ័ដាមនិងអេវ៉ាបានចាកចេញពីសួនច្បារអេដែន អំពើបាបបានក្លាយទៅជាបញ្ហាដ៏ធំសម្រាប់ពួកគេ។ សូម្បីតែកាអ៊ីន ដែលជាកូនរបស់អ័ដាម និងអេវ៉ាបានសម្លាប់ ប្អូនប្រុសរបស់ខ្លួនគឺអេបិល ដោយព្រោះតែកំហឹង និងភាពច្រណែន។ ចាប់តាំងពីពេលនោះមក មនុស្សនៅតែធ្វើអំពើអាក្រក់ និងឈប់ស្ដាប់បង្គាប់ព្រះតែម្ដង។ ព្រះគឺពិតជាឈឺចាប់ខ្លាំងណាស់ ហើយព្រះអង្គបានសម្រេចថានឹងកំចាត់មនុស្សមានបាបទាំងអស់នោះចេញ។ គឺមានតែណូអេម្នាក់ប៉ុណ្ណោះដែលនៅតែបន្តថ្វាយបង្គំ និងស្ដាប់បង្គាប់ព្រះ។

ថ្ងៃមួយព្រះបានប្រាប់ណូអេថានឹងមានព្យុះដ៏ធំមួយ។ វានិងបណ្ដាលឲ្យមានភ្លៀងធ្លាក់ជាខ្លាំង។ ហើយទឹកជំនន់ក៏កើតមានដែរ។ ព្រះចង់ថែរក្សាណូអេឲ្យមានសុវត្ថិភាព ដូច្នេះព្រះអង្គបានប្រាប់ណូអេឲ្យសង់ទូកដ៏ធំមួយ។ នៅពេលដែលព្រះបានសុំយើងឲ្យធ្វើអ្វីមួយសម្រាប់ព្រះអង្គ គឺទ្រង់មិនដែលទុកឲ្យយើងធ្វើវាតែឯងនោះទេ ប៉ុន្តែព្រះអង្គគឺតែងតែជួយដល់យើង។ ណូអេបានចំណាយពេលពីមួយឆ្នាំទៅមួយឆ្នាំដើម្បីធ្វើទូកដ៏ធំមួយនោះ។ ព្រះបានដឹងថា ណូអេត្រូវចំណាយពេលប៉ុនណាក្នុងការធ្វើទូកនោះ ដូច្នេះព្រះអង្គបានទុកពេល ជាច្រើនសម្រាប់ណូអេ មុនពេលទឹកជំនន់មកដល់។

ព្រះក៏បានដឹងដែរថាតើសម្ភារៈប្រភេទណាដែលគួរតែយកមកធ្វើទូកនោះ។ ព្រះបានប្រាប់ឲ្យណូអេប្រើដើមឈើល្អៗក្នុងការសង់ទូក។ ណូអេបានកាប់ឈើនោះ។ ណូអេបានដំ ឈើនោះ។ ហើយទូកក៏ចេះតែធំឡើងៗ។ ណូអេបានធ្វើតាមការណែនាំរបស់ព្រះ ព្រោះគាត់ដឹងថាទ្រង់តែងតែធ្វើនូវអ្វីដែលត្រឹមត្រូវ។

បន្ទាប់មក ផែនការរបស់ព្រះសម្រាប់ទូកបានចាប់ផ្ដើម។ សព្វសត្វទាំងអស់ក៏ចាប់ផ្ដើមចូលមកក្នុងទូក។ គ្រប់សត្វទាំងអស់មានទាំងញី និងឈ្មោល ណូអេក៏បានចូលទៅក្នុងទូក។ ណូអេក៏បានស្វែងរកកន្លែងសម្រាប់សត្វតាមពូជទាំងអស់។ ព្រះចង់ឲ្យសត្វទាំងអស់មានសុវត្ថិភាពនៅក្នុងទូកនៅពេលដែលមានខ្យល់ព្យុះបក់មក។ មិនយូរប៉ុន្មានភ្លៀងក៏ចាប់ផ្ដើមធ្លាក់។ ប៉ុន្តែណូអេ និងសត្វផ្សេងទៀតមានសុវត្ថិភាព និងមានភាពសប្បាយរីករាយនៅក្នុងទូក ពីព្រោះព្រះដឹងពីរបៀបដែលធ្វើឲ្យពួកគេមានសុវត្ថិភាព។ ព្រះគឺតែងតែធ្វើនូវរឿងត្រឹមត្រូវជានិច្ច។

ផ្លូវមួយដែលយើងគួរតែរៀននោះគឺ យើងត្រូវតែរៀនទុកចិត្តព្រះ រៀនស្ដាប់ព្រះសូរសៀងរបស់ព្រះអង្គ ហើយទុកឲ្យទ្រង់ជាអ្នកដឹកនាំផ្លូវយើង។ ពួកយើងបានធ្វើខុសពីមួយលើកទៅមួយលើក នេះគឺជាផ្នែកមួយនៃធម្មជាតិជាមនុស្ស។ ប៉ុន្តែព្រះគឺប្រសើរជាងយើងឆ្ងាយណាស់។ ព្រះអង្គទ្រង់ជ្រាបដឹងគ្រប់យ៉ាង! សូមចាំថា ព្រះគឺតែងតែធ្វើនូវរឿងត្រឹមត្រូវ ហើយយើងគឺអាចទុកចិត្តទ្រង់បាននិច្ចផងដែរ។

## ៦. សំនួរពិភាក្សា

១. ហេតុអ្វីបានជាព្រះមិនសប្បាយព្រះទ័យ?

*(ពីព្រោះមនុស្សនៅតែប្រព្រឹត្តអំពើបាប និងឈប់ស្ដាប់បង្គាប់ព្រះ)*

២. ហេតុអ្វីបានជាព្រះជ្រើសរើសណូអេ?

*(ពីព្រោះគាត់គឺជាម្នាក់ដែលនៅបន្តថ្វាយបង្គំព្រះ និងស្ដាប់បង្គាប់ទ្រង់)*

៣. តើព្រះបានប្រាប់ឲ្យណូអេធ្វើអ្វី? *(ធ្វើទូកធំមួយសម្រាប់សត្វគ្រប់ពូជ និងក្រុមគ្រួសាររបស់គាត់)*

៤. តើព្រះបានធ្វើដូចម្ដេចបន្ទាប់ពីបានប្រាប់ឲ្យណូអេសង់ទូកនោះ?

*(ព្រះបានប្រាប់ណូអេពីផែនការ និងបានបង្ហាញផ្លូវដល់គាត់ ដូច្នេះណូអេដឹងថាគាត់ត្រូវធ្វើអ្វី នៅពេលដែល ព្រះប្រាប់ឲ្យយើងធ្វើអ្វីមួយទ្រង់តែងតែបង្ហាញផ្លូវយើង ដូច្នេះយើងអាចធ្វើកិច្ចការទាំងអស់នោះបាន)*

៥. តើមានហេតុផលអ្វីដែលធ្វើឲ្យអ្នកគិតថាព្រះគឺតែងតែត្រឹមត្រូវ? *(ទុកឲ្យកុមារជាអ្នកឆ្លើយ)*

**៧. ល្បែងកំសាន្ត** «សាងសង់ប៉ម»



សម្ភារៈដែលត្រូវការ៖ កែវប្លាស្ទិក ៤០ ក្រដាសកេស ឬក្រដាសកាតុង (កាត់ជារាងចតុកោណកែង)

១. ចែកកុមារជា ២ក្រុម ហើយឲ្យកែវ ២០ និងក្រដាសកាតុង កាត់រួច ៣ បំណែក

២. ក្រុមនីមួយៗ ត្រូវធ្វើប៉មបញ្ច្រាស់។ ជួរទី ១ មានកែវពីរ ហើយដាក់ក្រដាសកាតុងពីលើ។ បន្ទាប់មកដាក់កែវ ៤ សម្រាប់ជួរទី២ ហើយដាក់ក្រដាសកាតុងពីលើ។ បន្ទាប់មកដាក់កែវ ៦ សម្រាប់ជួរទី៣ ហើយដាក់ក្រដាសកាតុងពីលើ។ សម្រាប់ជួរចុងក្រោយ ដាក់កែវ៨ ពីលើក្រដាសកាតុង។

៣. ក្រុមដែលអាចធ្វើរួចមុន ដោយមិនឲ្យប៉មដួលនោះក្រុមរបស់ពួកគេជាអ្នកឈ្នះ។

៤. បន្ទាប់ពិលេងល្បែងនេះចប់ សូមពន្យល់កុមារថា ពេលគេធ្វើតាមការណែនាំរបស់គ្រូ គេអាចសង់ប៉មមួយ ដែលធ្វើពីកែវបាន។ ពេលណូអេធ្វើតាមការណែនាំរបស់ព្រះ គាត់អាចសង់ទូកធំមួយដើម្បីសង្គ្រោះសត្វទាំងអស់បាន។ ដូចគ្នានេះដែរ យើងត្រូវតែដើរតាមមាគ៌ារបស់ព្រះជានិច្ច បើទោះបីជាវាហាក់ដូចជាពិបាក ឬមិនអាចទៅរួច ដោយសារព្រះទ្រង់ត្រឹមត្រូវជានិច្ច។

**៨. ខគម្ពីរចងចាំ**

**លោកុប្បត្តិ ៦៖២២** *"ណូអេក៏ធ្វើដូច្នោះ តាមគ្រប់ទាំងសេចក្ដីដែលព្រះបានបង្គាប់ គាត់ធ្វើការនោះសំរេចទាំងអស់។"*

**៩. ហត្ថកម្ម** «លោកណូអេសង់ទូកធំមួយ»



សម្ភារៈដែលត្រូវការ៖ ព្រីនក្រដាសហត្ថកម្ម កូល័រ កន្ត្រៃ ដងឈើការ៉េម និងការបិត

១. ឲ្យក្រដាសហត្ថកម្មទៅកុមារម្នាក់មួយសន្លឹក ហើយឲ្យពួកគេតុបតែងវា។

២. កាត់រូបទូកនោះចេញមក ហើយបត់ទូកនោះជា២តាមបន្ទាត់ដាច់ៗ។

៣. បិតដងឈើការ៉េមនៅកណ្ដាលផ្នែកសមុទ្រ ហើយបិតផ្នែកទូកទាំង២ភ្ជាប់គ្នា។

៤. ហើយឥឡូវនេះអ្នកមានផ្នែកមួយនៃទូកដែលណូអេកំពុងតែសង់ ហើយផ្នែកមួយទៀតគឺនៅពេលដែលទូកបានធ្វើរួច។

៥. សូមពន្យល់ទៅកុមារថា ការដែលសង់ទូកដ៏ធំ ដែលអាចដាក់សត្វគ្រប់ប្រភេទបាន គឺមិនមែនជារឿងដែលអាចទៅរួចនោះទេសម្រាប់ណូអេ។ ប៉ុន្តែនៅពេលគាត់ស្ដាប់បង្គាប់ព្រះ ព្រះអង្គបានធ្វើឲ្យរឿងនោះក្លាយទៅជាការពិត! ហើយណូអេបានរៀនថា ព្រះគឺតែងតែត្រឹមត្រូវជានិច្ច!

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
ព្រះយេស៊ូវបានស្ដាប់បង្គាប់ព្រះនៅគ្រប់កាលៈទេសៈទាំងអស់នៅក្នុងជីវិតរបស់ព្រះអង្គ។ នៅពេលដែលយើងសំឡឹងមើលទៅកាន់ព្រះយេស៊ូវ និងដើរតាមគំរូរបស់ព្រះអង្គ នោះយើងនឹងស្ដាប់បង្គាប់ព្រះ។ តើនៅពេលណាដែលព្រះបានប្រាប់ទិសដៅដល់អ្នកក្នុងការធ្វើអ្វីមួយនោះ? តើការនោះបានធ្វើឲ្យអ្នកមានអារម្មណ៍ដូចម្ដេច?ពេលខ្លះវាហាក់ដូចជាគួរឱ្យខ្លាច ប៉ុន្តែវាក៏គួរឱ្យរំភើបផងដែរ ពីព្រោះព្រះបង្ហាញពីភាពស្មោះត្រង់ និងកម្លាំងរបស់ទ្រង់ នៅពេលយើងស្ដាប់បង្គាប់ទ្រង់ក្នុងកិច្ចការដែលទ្រង់សុំឱ្យយើងធ្វើ។ ចូរទទួលការសម្រាលទុក្ខ ដោយដឹងថាពេលអ្នកស្ដាប់បង្គាប់ព្រះទ្រង់នឹងប្រទានគ្រប់យ៉ាង ដែលអ្នកត្រូវការ ដើម្បីអនុវត្តផែនការរបស់ព្រះអង្គ។



សម្ភារៈដែលត្រូវការ៖ ព្រីនក្រដាសសហគ្គកម្មកូល័រ កន្ត្រៃ ដងឈើការ៉េម និងកាវបិត

១. ឲ្យក្រដាសសហគ្គកម្មទៅកុមារម្នាក់ មួយសន្លឹក ហើយឲ្យពួកគេគុបតែងវា

២. កាត់រូបទូកនោះចេញមក ហើយបត់ទូកនោះជា២តាមបន្ទាត់ដាច់ៗ។

៣. បិតដងឈើការ៉េមនៅកណ្ដាលក្នុងផ្នែកសមុទ្រ ហើយបិតផ្នែកទូក ទាំង២ភ្ជាប់គ្នា។

៤. ហើយឥឡូវនេះអ្នកមានទូក ដែលផ្នែកមួយគឺ ណូអេកំពុងតែសង់ទូក ហើយផ្នែកមួយទៀត គឺនៅពេលដែលទូកបានធ្វើច។

៥.សូមពន្យល់ទៅកុមារថា ការ ដែលសង់ទូកដ៏ធំ ដែលអាចដាក់ សត្វគ្រប់ប្រភេទបាន គឺមិនមែន ជារឿងដែលអាចទៅរួចនោះទេ សម្រាប់ណូអេ។ ប៉ុន្តែនៅពេល គាត់ស្ដាប់បង្គាប់ព្រះ ព្រះអង្គបាន ធ្វើឲ្យរឿងនោះក្លាយទៅជាការពិត! ហើយណូអេបានរៀនថា ព្រះគឺតែងតែត្រឹមត្រូវជានិច្ច!





សម្ភារៈដែលត្រូវការ៖ ព្រីនក្រដាសសហគ្គកម្មកូល័រ កន្ត្រៃ ដងឈើការ៉េម និងកាវបិត

១. ឲ្យក្រដាសសហគ្គកម្មទៅកុមារម្នាក់ មួយសន្លឹក ហើយឲ្យពួកគេគុបតែងវា

២. កាត់រូបទូកនោះចេញមក ហើយបត់ទូកនោះជា២តាមបន្ទាត់ដាច់ៗ។

៣. បិតដងឈើការ៉េមនៅកណ្ដាលក្នុងផ្នែកសមុទ្រ ហើយបិតផ្នែកទូក ទាំង២ភ្ជាប់គ្នា។

៤. ហើយឥឡូវនេះអ្នកមានទូក ដែលផ្នែកមួយគឺ ណូអេកំពុងតែសង់ទូក ហើយផ្នែកមួយទៀត គឺនៅពេលដែលទូកបានធ្វើច។

៥.សូមពន្យល់ទៅកុមារថា ការ ដែលសង់ទូកដ៏ធំ ដែលអាចដាក់ សត្វគ្រប់ប្រភេទបាន គឺមិនមែន ជារឿងដែលអាចទៅរួចនោះទេ សម្រាប់ណូអេ។ ប៉ុន្តែនៅពេល គាត់ស្ដាប់បង្គាប់ព្រះ ព្រះអង្គបាន ធ្វើឲ្យរឿងនោះក្លាយទៅជាការពិត! ហើយណូអេបានរៀនថា ព្រះគឺតែងតែត្រឹមត្រូវជានិច្ច!

